ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល (NSW Health)

វ៉ាក់សាំងជំងឺស្វិតដៃជើង

សន្លឹកព័ត៌មានសម្រាប់ឪពុកម្តាយ

រដ្ឋាភិបាលអូស្ត្រាលីផលិតវ៉ាក់សាំងមួយចំនួនដោយឥតគិតថ្លៃនៅក្រោមកម្មវិធីចាក់ថ្នាំបង្ការថ្នាក់ជាតិ (NIP)។

សំណួរ៖ តើជំងឺស្វិតដៃជើងជាអ្វី?

ជំងឺស្វិតដៃជើងគឺជាមេរោគឆ្លងមួយដែលអាចបណ្តាលឱ្យខ្វិន និងស្លាប់។ មនុស្សភាគច្រើនដែលមានជំងឺស្វិតដៃជើង មិនមានរោគសញ្ញាអ្វីនោះទេ។ ប្រហែល 10% អាចមានគ្រុនក្តៅ ឈឺក្បាល អស់កម្លាំង ចង្អោរ និងក្អួត ប៉ុន្តែជាធម្មតាពួកគេជាសះស្បើយឡើងវិញ។

ក្នុងប្រហែល 2% នៃករណី វីរុសបង្កឱ្យមានការឈឺសាច់ដុំធ្ងន់ធ្ងរ និងរឹងនៅខ្នង ឬក។ តិចជាង 1% វិវត្តទៅជាខ្វិន ដែលអាចប៉ះពាល់ដល់ដៃ ជើង ក ឬសាច់ដុំដកដង្ហើម។

សំណួរ៖ តើជំងឺស្វិតដៃជើងឆ្លងរាលដាលយ៉ាងដូចម្តេចដែរ?

ជំងឺស្វិតដៃជើងឆ្លងតាមរយៈការប៉ះពាល់លាមក ឬទឹកមាត់តិចតួចពីមនុស្សដែលបានឆ្លងរោគ។ នេះអាចកើតឡើងប្រសិនបើមិនបានលាងសម្អាតដៃឱ្យបានត្រឹមត្រូវ។

វីរុសចូលតាមច្រមុះ ឬមាត់ ឆ្លងរោគចូលពោះវៀន ហើយអាចរាលដាលដល់ឈាម និងប្រព័ន្ធប្រសាទ។ មនុស្សដែលមានជំងឺស្វិតដៃជើងគឺឆ្លងច្រើនបំផុត 10 ថ្ងៃមុនពេលមានរោគសញ្ញារហូតដល់ 10 ថ្ងៃបន្ទាប់ពីរោគសញ្ញាលេចឡើង។

សំណួរ៖ តើវ៉ាក់សាំងដំណើរការយ៉ាងដូចម្តេច?

វ៉ាក់សាំងជួយប្រព័ន្ធភាពស៊ាំប្រឆាំងនឹងការឆ្លងរោគ។ ប្រសិនបើមនុស្សដែលបានចាក់វ៉ាក់សាំងត្រូវបានប៉ះពាល់នឹងវីរុស រាងកាយរបស់ពួកគេអាចប្រយុទ្ធប្រឆាំងនឹងជំងឺបានល្អជាង ឬធ្វើឱ្យវាមិនសូវធ្ងន់ធ្ងរ។

សំណួរ៖ តើវ៉ាក់សាំងកជំងឺស្វិតដៃជើងមានប្រសិទ្ធភាពយ៉ាងណាដែរ?

វគ្គពេញលេញនៃវ៉ាក់សាំងជំងឺស្វិតដៃជើង (3 ដូស) មានប្រសិទ្ធភាព 99% ក្នុងការទប់ស្កាត់ជំងឺនេះ។

សំណួរ៖ តើអ្នកណាគួរចាក់វ៉ាក់សាំង?

ក្មេងជំទង់ដែលមិនទាន់បានចាក់វ៉ាក់សាំងជំងឺស្វិតដៃជើងទាំង 3 ដូស គួរតែត្រូវបានចាក់វ៉ាក់សាំង។

សំណួរ៖ តើអ្នកណាមិនគួរចាក់វ៉ាក់សាំង?

កុំចាក់វ៉ាក់សាំងដល់មនុស្សដែល៖

- **មានប្រតិកម្មអាលែហ្សីធ្ងន់ធ្ងរ (អាណាហ្វីឡាក់ទិច) ទៅនឹងដូសពីមុន**
- **មានប្រតិកម្មអាលែហ្សីធ្ងន់ធ្ងរចំពោះធាតុផ្សំនៅក្នុងវ៉ាក់សាំង។**

សំណួរ៖ តើអ្វីទៅប្រតិកម្មអាណាហ្វីឡាក់ទិច (anaphylaxis)?

ប្រតិកម្មអាណាហ្វីឡាក់ទិចគឺជាប្រតិកម្មអាលែហ្សីដ៏កម្រ ប៉ុន្តែធ្ងន់ធ្ងរ។ វាអាចបណ្តាលឱ្យសន្លប់ ឬស្លាប់ ប្រសិនបើមិនបានព្យាបាលឱ្យបានឆាប់រហ័ស។ អ្នកផ្តល់សេវាចាក់ថ្នាំបង្ការត្រូវបានបណ្តុះបណ្តាលដើម្បីគ្រប់គ្រងប្រតិកម្មអាណាហ្វីឡាក់ទិចនេះ។

សំណួរ៖ ចុះបើខ្ញុំមិនដឹងថាកូនរបស់ខ្ញុំបានចាក់វ៉ាក់សាំងការពារជំងឺស្វិតដៃជើងឬអត់?

ប្រសិនបើអ្នកមិនមានកំណត់ត្រាទេ កូនរបស់អ្នកនៅតែអាចចាក់វ៉ាក់សាំងបានដោយសុវត្ថិភាព។

សំណួរ៖ តើអ្វីជាវ៉ាក់សាំងការពារជំងឺស្វិតដៃជើង?

វ៉ាក់សាំងនេះមានផ្ទុកបរិមាណតិចតួចនៃ៖

- **phenoxyethanol, formaldehyde និង polysorbate 80**
- **neomycin, streptomycin, និង polymyxin B**
- **អាល់ប៊ុមប៊ីនសេរ៉ូម។**

សារធាតុផ្សំទាំងនេះជួយឱ្យវ៉ាក់សាំងដំណើរការ ឬរក្សាវាបានយូរ។ វាក៏ត្រូវបានប៉ះពាល់ទៅនឹងសារធាតុពីសន្តានគោផងដែរនៅក្នុងអំឡុងពេលផលិត។

សំណួរ៖ តើវ៉ាក់សាំងមានសុវត្ថិភាពប៉ុណ្ណាដែរ?

វ៉ាក់សាំងនៅប្រទេសអូស្ត្រាលីមានសុវត្ថិភាពណាស់។ វ៉ាក់សាំងត្រូវតែឆ្លងកាត់ការត្រួតពិនិត្យសុវត្ថិភាពយ៉ាងតឹងរឹង មុនពេលមានការអនុម័តដោយរដ្ឋបាលគ្រប់គ្រងលើទំនិញទាក់ទងនឹងការព្យាបាល (TGA)។ TGA ក៏តាមដានលើសុវត្ថិភាពវ៉ាក់សាំងផងដែរបន្ទាប់ពីការប្រើប្រាស់រួច។

សំណួរ៖ តើវ៉ាក់សាំងជំងឺស្វិតដៃជើងមានផលប៉ះពាល់បន្ទាប់បន្សំអ្វីខ្លះ?

ផលប៉ះពាល់បន្ទាប់បន្សំជាធម្មតាស្រាល ហើយអាចរួមមាន៖

- **ភាពក្រហម ការឈឺចាប់ ឬការហើមនៅកន្លែងចាក់វ៉ាក់សាំង**
- **គ្រុន។**

ផលប៉ះពាល់បន្ទាប់បន្សំធ្ងន់ធ្ងរគឺកម្រណាស់។

សម្រាប់ព័ត៌មានបន្ថែម សូមពិនិត្យមើលព័ត៌មានអំពីឱសថសម្រាប់អ្នកប្រើប្រាស់ (CMI) នៅតាមគេហទំព័រ health.nsw.gov.au/schoolvaccination។ ប្រសិនបើអ្នកព្រួយបារម្ភអំពីផលប៉ះពាល់បន្ទាប់បន្សំ សូមទាក់ទង GP (វេជ្ជបណ្ឌិតព្យាបាលជំងឺទូទៅ) របស់អ្នក។